**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦១)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្ដីរបស់ យឹម ទិត្យ

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Mar-2020, 08:48
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី**

សូ មូស្សេទ្ទី
Suzana TOMANOVIĆ

**<u>ផ្ញើជូន៖</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហួត វុទ្ធី

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

ចៅក្រមបម្រុង Steven J. BWANA

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤**

## សេចក្តីផ្តើម

១. លោក **យឹម ទិត្យ** តាមរយៈសហមេធាវីការពារក្តីរបស់ខ្លួន ("មេធាវីការពារក្តី") សូមដាក់ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ("ចម្លើយតប")។ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានសម្រេចជាឯកច្ឆ័ន្ទនៅក្នុងសំណុំរឿង ០០៤/០២ ថា សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") គ្មានមូលដ្ឋាន ច្បាប់ក្នុងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នាចំនួនពីរនោះទេ។ ការធ្វើបែបនេះមានន័យថា ដីកាដំណោះស្រាយពីរដែលសហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញនៅក្នុងសំណុំរឿង ០០៤ ខុសច្បាប់ ហេតុដូច្នេះ ត្រូវចាត់ទុកជាមោឃៈ[1]។ សេចក្តីសន្និដ្ឋានទាំងអស់អំពីអង្គសេចក្តីនៃដីកាដំណោះស្រាយ ពុំមានការពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះទេ ដែលធ្វើឲ្យបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពុំអាចយកជាការបាន។ អាស្រ័យហេតុនេះ អ.ប.ជ គួរច្រានចោលដីកាដំណោះស្រាយដែលមានវិការៈនេះ និងអាចថា (i) លើកលែងការចោទប្រកាន់ទាំងស្រុងជាអចិន្ត្រៃយ៍ និងលើកលែងរឿងក្តីនេះប្រឆាំងនឹងលោក យឹម ទិត្យ (ii) បង្វិលសំណុំរឿងទៅ ស.ច.ស វិញ ដើម្បីចេញដីកាដំណោះស្រាយរួមគ្នាមួយ ឬក៏ (iii) វាយតម្លៃសំណុំរឿង ០០៤ រួចហើយចេញដីកាដំណោះ ស្រាយដោយខ្លួនឯង។

## ប្រវត្តិនីតិវិធី

២. មេធាវីការពារក្តីបញ្ចូលប្រវត្តិនីតិវិធី ដែលមាននៅក្នុង *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងសេចក្តីសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* [2] នៅក្នុង *បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤*[3] និងនៅក្នុង *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត*

---

[1] *ដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ* ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381។ *ដីកាដំណោះស្រាយ* ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

[2] *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D378/5 កថាខណ្ឌ ១៤-១០៥។

[3] *បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/18 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ") កថាខណ្ឌ ៤-១០។

*អន្តរជាតិ ក្នុងសំណុំរឿង ០០៤*[4]។

៣. នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ស.ព.អ បានដាក់*បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ* ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ")[5]។

៤. នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់*បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិក្នុងសំណុំរឿង ០០៤*[6]។

៥. នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់ *សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*[7] ។ ស.ព.អ បានឆ្លើយតបនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩[8]។

៦. នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ អ.ប.ជ បានចេញ*សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤*[9]។

---

[4] *បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D382/22 កថាខណ្ឌ ៣-៩។

[5] *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ (D381)* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/19។

[6] *បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/20។

[7] *សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបរបស់គាត់ ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/21 និង D382/23។

[8] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់របស់ យឹម ទិត្យ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/23 និង D382/25។

[9] *សេចក្តីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤* ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ឯកសារ D381/24 និង D382/26។

## ចម្លើយតប ÷ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ មិនអាចយកជាការបាន

៧. បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ មិនអាចយកជាការបានទាំងស្រុងតែម្តង ដោយសារ (i) អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទនៅក្នុងសំណុំរឿង ០០៤/០២ ថា ស.ច.ស គ្មានមូលដ្ឋានច្បាប់ក្នុងការ ចេញដីកាដំណោះស្រាយពីរនោះទេ (ii) អាស្រ័យហេតុនេះ ដីកាដំណោះស្រាយទាំងពីរនៅក្នុងសំណុំរឿង ០០៤ ត្រូវចាត់ទុកជាមោឃៈ ហើយ ជាលទ្ធផល (iii) មូលដ្ឋានបណ្តឹងឧទ្ធរណ៍ទាំងអស់អំពីអង្គសេចក្តីនៃដីកាដំណោះស្រាយ ពុំពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន។

## I. ការចេញដីកាដំណោះស្រាយចំនួនពីរពុំមានមូលដ្ឋានផ្លូវច្បាប់ទេ

៨. ចៅក្រម អ.ប.ជ បានចុះហត្ថលេខាលើសេចក្តីសម្រេចជាឯកច្ឆ័ន្ទនៅក្នុងសំណុំរឿង ០០៤/០២ ដែល "ប្រកាសថា ការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក"[10]។

៩. អ.ប.ជ បានសម្រេចថា ស.ច.ស "បានប្រព្រឹត្តកំហុសអង្គច្បាប់ដ៏ធំធេង"[11] ដោយ "បានចេញដីកាដំណោះស្រាយផ្សេងគ្នា ផ្ទុយគ្នាក្នុងពេលតែមួយ ដែលមិនធ្លាប់មានពីមុនមក នៅក្នុងសំណុំរឿងតែមួយ"[12] ហើយ ស.ច.ស បាន "រំលោភបំពានទៅលើក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក ប្រាសចាកពីតួនាទីខ្ពស់បំផុតរបស់ពួកគេ និងបង្កើតជាស្ថានភាពគតិយុត្តដែលមិនធ្លាប់មាន ដែលធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋានសំខាន់ៗនៃអង្គភាពតុលាការរបស់ពួកគេ"[13]។ អ.ប.ជ "បានប្រកាសថ្កោលទោសយ៉ាងច្បាស់លាស់ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើប្រព័ន្ធច្បាប់របស់ អ.វ.ត.ក នេះ" និងបានសម្រេចថា ស.ច.ស បាន "រំលោភបំពានទៅលើមូលដ្ឋានផ្ទាល់នៃប្រព័ន្ធច្បាប់របស់ អ.វ.ត.ក"[14]។

១០. អ.ប.ជ បានសម្រេចយ៉ាងច្បាស់ និងគ្មានស្រពិចស្រពិលថា យោងតាមក្របខ័ណ្ឌគតិយុត្តរបស់

---

[10] *សំណុំរឿង ០០៤/២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 ("សេចក្តីពិចារណាលើសំណុំរឿង ០០៤/២) ទំព័រ ៦១។

[11] *ដូចខាងលើ* កថាខណ្ឌ ៩៨ និង ៩៩។

[12] *ដូចខាងលើ* កថាខណ្ឌ ៨៨។

[13] *ដូចខាងលើ* កថាខណ្ឌ ៨៩។

[14] *ដូចខាងលើ* កថាខណ្ឌ ១០០ និង ១០២។

អ.វ.ត.ក ដីកាដំណោះស្រាយត្រូវតែជាសេចក្ដីសម្រេចតែមួយ ហើយក្របខ័ណ្ឌនេះពុំបានអនុញ្ញាតឲ្យចេញដីកាដំណោះស្រាយដាច់ចេញពីគ្នានោះទេ[15]។ អ.ប.ជ យល់ថា វិធាន ៦៧(១) "ចែងច្បាស់" ថា ស.ច.ស "ត្រូវ" បញ្ចប់កិច្ចស៊ើបសួរ ដោយចេញ "ដីកាដំណោះស្រាយថា ត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ"[16]។ អ.ប.ជ យល់ឃើញថា សទ្ទានុក្រមនៅក្នុងវិធានផ្ទៃក្នុងចែងថា "ដីកាដំណោះស្រាយសំដៅទៅលើដីកាចុងក្រោយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ដំណើរការស៊ើបសួរ *ដែលអាចជា* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់"[17]។ អ.ប.ជ ក៏បានបង្ហាញហេតុផល ផងដែរថា ខប្បញ្ញត្តិបកស្រាយនៅក្នុងវិធាន ១(២) "មិនបានផ្ដល់មូលដ្ឋានគតិយុត្តគ្រប់គ្រាន់ ដើម្បីទាត់ចោល ឬកាត់បន្ថយគោលការណ៍ស្នូលនៃកិច្ចព្រមព្រៀង អ.វ.ត.ក [...] ទាមទារសិទ្ធិអំណាចក្នុងការបំពេញកិច្ចនៅពេលដែលផលប៉ះពាល់ដោយសារការអនុវត្តសិទ្ធិអំណាចបែបនេះអាចមានទំនាស់ជាមួយគោលការណ៍ទាំងអស់នេះ"[18]។ អ.ប.ជ បានសន្និដ្ឋានដោយបញ្ជាក់ថា៖

---

[15] *ដូចខាងលើ* កថាខណ្ឌ ១២០ ដល់ ១២១។

[16] *ដូចខាងលើ* កថាខណ្ឌ ១២១ (សង្កត់ន័យបន្ថែមដោយអក្សរទ្រេតនៅក្នុងឯកសារដើម)។ ក្របខណ្ឌច្បាប់សម្រាប់ អ.វ.ត.ក ចែងគាំទ្របន្ថែម។ នៅក្រោមមាត្រា ៥(៤) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង រវាង អ.ស.ប និង រ.រ.ក") ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ ស.ច.ស ត្រូវ "សហការគ្នាដើម្បីឈានទៅដល់ការងារឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត"។ នៅក្រោមមាត្រា ២៣*ថ្មី* នៃច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ រួមទាំងការដាក់បញ្ចូលនូវវិសោធនកម្មដែលបានប្រកាសឲ្យប្រើកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក") ចែងថា រាល់ការស៊ើបអង្កេតគឺជា "ការទទួលខុសត្រូវរួមរបស់ចៅក្រមពីរនាក់"។ វិធាន ១៤ នៃវិធានផ្ទៃចែងសំដៅថា ស.ច.ស ត្រូវបំពេញកិច្ចស៊ើបសួររួមគ្នា និងមានអំណាចស្មើគ្នា ហើយបទប្បញ្ញត្តិនេះមិនសំដៅឲ្យ ស.ច.ស បំពេញកិច្ចតែម្នាក់ឯងដើម្បីចេញដីកាដំណោះស្រាយ (ជាពិសេស លក្ខខណ្ឌនៃវិធាន ១៤(៤) នោះទេ ដែលក្នុងនោះ ការចេញដីកាដំណោះស្រាយ គឺជាកិច្ចដែលត្រូវ "បំពេញរួមគ្នាដូចមានចែងក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធានទាំងនេះ" ហើយហេតុដូច្នេះ វិធានផ្ទៃក្នុងពុំអនុញ្ញាតឲ្យផ្ទេរភារកិច្ចឡើយ)។ ចុងក្រោយបំផុត ពុំមានការសំអាងនៅត្រង់ណាមួយក្នុងកិច្ចព្រមព្រៀង រវាង អ.ស.ប និង រ.រ.ក ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឬវិធានផ្ទៃក្នុង ចំពោះលទ្ធភាពក្នុងការចេញជាឯកតោភាគី នូវដីកាដំណោះស្រាយមួយដាច់ដោយឡែកពីគ្នាដោយ ស.ច.ស តែម្នាក់នោះទេ កថាខណ្ឌ ២២ ដល់ ៣០។

[17] សេចក្ដីពិចារណាលើសំណុំរឿង ០០៤/២ កថាខណ្ឌ ១២១ ដកស្រង់ចេញពីវិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ៨៣។ (សង្កត់ន័យបន្ថែមដោយអក្សរទ្រេតនៅក្នុងឯកសារដើម)។

[18] *ដូចខាងលើ* កថាខណ្ឌ ១២១។

កំហុសដែលសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តនៅក្នុងសំណុំរឿងនេះ ធ្វើឲ្យខូចខាតដល់មូលដ្ឋាននៃប្រព័ន្ធចម្រុះ និងមុខងារដ៏ត្រឹមត្រូវរបស់ អ.វ.ត.ក។ ទោះបីជាបញ្ហានៅចំពោះមុខមានភាពធ្ងន់ធ្ងរ និងផុយស្រួយក្ដី ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតនៅតែអនុញ្ញាតឲ្យខ្លួនឯងចេញដីកាដំណោះស្រាយ ដែលមានសំអាងហេតុតិចតួចឲ្យកត់សម្គាល់ ដើម្បីផ្ដល់យុត្តិកម្មដល់សកម្មភាពរបស់ខ្លួនដោយគ្រាន់តែរម្លឹកអំពីសេចក្ដីសម្រេចរបស់ខ្លួនមួយនាពេលកន្លងមកប៉ុណ្ណោះ។ ជាពិសេស អង្គជំនុំជម្រះយល់ឃើញថា ជារឿងគួរឲ្យរំខានខ្លាំងដែលដីកាសម្រេចដាច់ពីគ្នានេះ ត្រូវបានចេញនៅថ្ងៃតែមួយ មួយភាសា *ដោយមានការប្រកាសយ៉ាងច្បាស់ដោយសហចៅក្រម ស៊ើបអង្កេតទាំងពីរថា ពួកគាត់បានឯកភាពគ្នាលើការចេញដោយខុសច្បាប់នូវដីកាដំណោះស្រាយដាច់ពីគ្នា ហើយផ្ទុយគ្នា*។ អង្គជំនុំជម្រះយល់ថា ការអនុវត្តដោយខុសឆ្គងរបស់សហចៅក្រម ស៊ើបអង្កេតនៅក្នុងករណីនេះ បង្កគ្រោះថ្នាក់ដល់ប្រព័ន្ធគតិយុត្តិទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ គួរឲ្យភ្ញាក់ផ្អើល ចៅក្រមស៊ើបអង្កេតបាន "ដឹង អំពីបញ្ហា" ដែលអាចកើតឡើងដោយសារតែដីកាដំណោះស្រាយដែលដាច់ពីគ្នា ជាពិសេស នៅដំណាក់កាលបណ្ដឹងឧទ្ធរណ៍នោះ [...][19]។

អង្គបុរេជំនុំជម្រះសម្ដែងការសោកស្ដាយ និងថ្កោលទោសយ៉ាងខ្លាំងចំពោះស្ថានភាពគតិយុត្តិដែលមិនធ្លាប់មានពីមុន ដោយសារតែសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេតបានបង្កឡើងចំពោះកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នរបស់ អ.វ.ត.ក[20]។

១១. ការសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤/០២ ត្រូវអនុវត្តដូចគ្នានៅក្នុងសំណុំរឿង ០០៤។ វិធាន ២១ ចែងអំពីសច្ចភាពផ្លូវច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធី[21]។ ក្រុមប្រឹក្សាជំនុំ

---

[19] *ដូចខាងលើ* កថាខណ្ឌ ១២៣។ (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។

[20] *ដូចខាងលើ* កថាខណ្ឌ ១២៤។

[21] អ.ប.ជ យល់ឃើញថា ខ្លួនត្រូវធានាថា "ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន [ត្រូវតែ] បកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព" នៅទូទាំងដំណាក់កាលមុនការជំនុំជម្រះ'។ *ដូចខាងលើ* កថាខណ្ឌ ៥១ ដកស្រង់វិធាន ២១។ "ចំណុចមួយ ក្នុងចំណោមចំណុចជាសារវន្តនៃនីតិរដ្ឋ គឺគោលការណ៍សច្ចភាពផ្លូវច្បាប់ ដែល*ក្នុងនោះ*ត្រូវថា នៅពេលដែលតុលាការបានសម្រេចលើបញ្ហាមួយជាស្ថាពរហើយ ការសម្រេចរបស់តុលាការមិនត្រូវចោទជាបញ្ហាទៀតឡើយ"។ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្ដីរវាង *Brumărescu* *ទល់នឹងប្រទេសរ៉ូម៉ានី* សំណុំរឿងលេខ ២៨៣៤២/៩៥ សាលក្រម ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦១។ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្ដីរវាង *Kehaya និងអ្នកផ្សេងទៀត ទល់នឹង ប្រទេសប៊ុលហ្គារី* សំណុំរឿងលេខ ៤៧៧៩៧/៩៥ និង ៦៨០៩៨/០១ សាលក្រម ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ កថាខណ្ឌ ៦១។ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្ដី

ជម្រះដដែលនេះបានបើកសវនាការលើបណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿង ០០៤ ហើយសំណុំរឿងទាំងពីរ ប្រឈមនឹងស្ថានភាពនីតិវិធីដូចគ្នា គឺ ដីកាដំណោះស្រាយផ្ទុយគ្នា។ អាស្រ័យហេតុនេះ ការសម្រេចជាឯកច្ឆ័ន្ទ និងជាក់លាក់របស់ អ.ប.ជ បានតម្កល់ទឡ្ហីករណ៍របស់មេធាវីការពារក្តី នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ[22]។ បច្ចុប្បន្ននេះ ច្បាស់ណាស់ថា ដីកាដំណោះស្រាយទាំងពីរដែលត្រូវបានជំទាស់ ហើយជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿង ០០៤ ពុំមានមូលដ្ឋាននៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ទេ។

## II. ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ និង ស.ច.ស.អ ត្រូវចាត់ទុកជាមោឃៈ

១២. អានុភាពនៃការសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ គឺថាដីកាដំណោះស្រាយទាំងពីរនៅក្នុងសំណុំរឿង ០០៤ ត្រូវចាត់ទុកជាមោឃៈ។ វាជាច្បាប់ទូទៅដែលថា ដីកាសម្រេចរបស់តុលាការពុំមានមូលដ្ឋានផ្លូវច្បាប់ ត្រូវចាត់ទុកជាមោឃៈ ដែលមានន័យថាដីកាសម្រេចនេះពុំមានអត្ថិភាពទាំងអង្គសេចក្តី និងទម្រង់ច្បាប់[23]។

---

រវាង Ryabykh *ទល់និងប្រទេសរូស្ស៊ី* សំណុំរឿងលេខ ៥២៨៥៤/៩៩ សាលក្រម ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៥១។ ["ក្នុងករណីដែលមានភាពខុសៗគ្នានៅក្នុងការអនុវត្តបទប្បញ្ញត្តិច្បាប់ស្រដៀងគ្នាមែនទែន នៅក្នុងក្រុមដែលស្មើរតែដូចគ្នា នោះបញ្ហាសច្ចភាពគតិយុត្តិពិតជាកើតឡើងមិនខាន"]។ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីរវាង *Ştefănică និងអ្នកផ្សេងទៀត ទល់នឹងប្រទេសរ៉ូម៉ានី* សំណុំរឿងលេខ ៣៨១១៥/០២ សាលក្រម ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៣៧ (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។ ការវិនិច្ឆ័យសេចក្តីមិនស៊ីសង្វាក់គ្នាលើពាក្យបណ្តឹងដែលបុគ្គលទាំងឡាយបានប្តឹង នៅក្នុងស្ថានភាពស្រដៀងៗគ្នា នាំឱ្យឈានដល់ស្ថានភាពមិនច្បាស់លាស់ ដែលនាំឱ្យបាត់បង់ទំនុកចិត្តសាធារណជនមកលើតុលាការ និងដកហូតពីបុគ្គលនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ *សូមើល* ដូចខាងលើ កថាខណ្ឌ ៣៨។

[22] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយ កថាខណ្ឌ ២៖ "នៅពេលជ្រើសរើសចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤ ចំនួនពីរផ្ទុយគ្នា និងដោយឡែកពីគ្នាបែបនេះ ទាំង ស.ច.ស.ជ និង ស.ច.ស.អ បានអនុវត្តផ្ទុយពី*រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ") ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* [...] និងវិធានផ្ទៃក្នុង។ ដីកាដំណោះស្រាយដែល ស.ច.ស ទាំងពីរានដាក់ជូន ត្រូវតែទទួលបានការបដិសេធ ដោយាសារវិការៈផ្នែកនីតិវិធី អនុលោមតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្តីសន្និដ្ឋានថា អ.ប.ជ ត្រូវតែអន្តាគមន៍នាពេលនេះ ដើម្បីបិទបញ្ចប់កិច្ចស៊ើបសួរពិតប្រាកដសម្រាប់លោក យឹម ទិត្យ ស្របតាមសិទ្ធិរបស់លោក និងដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់លោកក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌"។

[23] វចនានុក្រម Black's Law កំណត់និយមន័យពាក្យ *nullius juris* ថា "ពុំមានអានុភាពផ្លូវច្បាប់" ពាក្យ *void* ថា "ពុំមានសុពលភាពតាមផ្លូវច្បាប់, មោឃៈ" និង ពាក្យ a *void judgment* ថាជា "សាលក្រមដែលពុំមានអានុភាព ឬសុពល ភាពតាមផ្លូវច្បាប់ គឺអសុពលភាពដែលអាចត្រូវបានបញ្ជាក់អះអាងដោយភាគីណាមួយ ដែលសិទ្ធិរបស់ខ្លួនត្រូវបានរងផលប៉ះពាល់

១៣. ច្បាស់ណាស់ថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ត្រូវធ្វើឡើងស្របតាមច្បាប់ជាធរមាន[24]។ ដូច អ.ប.ជ បានទទួលស្គាល់ វិធាន ៦៧ គឺជាច្បាប់ជាធរមានសម្រាប់ចេញដីកាដំណោះស្រាយ[25]។

១៤. អនុលោមតាមវិធាន ៦៧(២) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ត្រូវចាត់ទុកជាមោឃៈដោយមានកំហុសនីតិវិធី" ប្រសិនបើពុំបានបង្ហាញ "បញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"[26]។ ដោយសារលក្ខខណ្ឌនៅក្នុងវិធាន ៦៧(២) មានលក្ខណៈជាក់លាក់ និងលក្ខណៈនៃ "មោឃៈភាព" ពុំមែនអាចចាត់ទុកជាមោឃៈ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានវិការៈផ្នែកនីតិវិធី ច្បាស់ណាស់ថា ដីកាដំណោះស្រាយដែលធ្វើឡើងដោយពុំគោរពច្បាស់ទៅនឹងច្បាប់នីតិវិធីរបស់ អ.វ.ត.ក នោះត្រូវចាត់ទុកជាមោឃៈ។ អ្នកធ្វើសេចក្តីព្រាងវិធាន ៦៧ ពុំបានប្រមើលមើលឃើញពីភាពបត់បែន

---

នៅពេលណាមួយ នៅកន្លែងណាមួយ ទោះបីជាដោយផ្ទាល់ ឬបន្ទាប់សន្សំក្តី។ ចាប់តាំងពីដើមដំបូងរបស់វាមក សាលក្រមដែលពុំមានអានុភាពផ្លូវច្បាប់ នៅតែបន្តមានអសុពលភាពជាដាច់ខាត។ សាលក្រមនេះមិនអាចត្រូវបានអះអាង ទទួលយក ឬអនុវត្តតាមរបៀបណាមួយ ឬក្នុងកម្រិតណាមួយបានឡើយ"។ Garner, B., [Ed.] វចនានុក្រម *Black's Law* បោះពុម្ពលើកទី៩ ទំព័រ ៩២១ ១១៧៣ និង ១៧០៩។

[24] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក ចែងការពារសិទ្ធិរបស់ជនជាប់ចោទ ស្របតាមមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ១៩៦៦ 999 UNTS 171 ('ICCPR')។ មាត្រា ១៤(១) នៃ ICCPR ចែងថា៖ "ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ"។ *សូមមើល* កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក មាត្រា ១៣(១)។ សូមមើល ផងដែរ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥*ថ្មី* ដែលចែងអំពីការអនុវត្តការធានាជាអប្បរមាក្នុងមាត្រា ១៤ នៃ ICCPR។ មាត្រា ៣៣*ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា ការជំនុំជម្រះរស់ អ.វ.ត.ក ត្រូវតែ "[...] ទៅតាមនីតិវិធីជាធរមាន [...]"។ មាត្រា ២១ នៃវិធានផ្ទៃក្នុងចែងថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង"។

[25] *សេចក្តីពិចារណាលើសំណុំរឿង ០០៤/២* ទំព័រ ៦១។

[26] វិធាន ៦៧(២)៖ "ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះត្រូវបញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើសដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"។

និងការប្រែប្រួលថ្មីនៃកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក នោះឡើយ។ ក្នុងករណីមានស្ថានការណ៍ខុសច្បាប់ដែល ស.ច.ស ចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ និងលើកលែងចោទនៅក្នុង ពេលតែមួយ នោះមានន័យថា *មានចន្លោះប្រហោង* នៅក្នុងវិធាន ៦៧។ ទោះបីជានៅក្នុងវិធាន ៦៧ ពុំបានលើកពីដំណោះស្រាយចំពោះការជាប់គាំងនីតិវិធីបច្ចុប្បន្នដែលចៅក្រម អ.ប.ជ កំពុងមានក៏ដោយ ក៏វិធាននេះចែងច្បាស់ថា ដីកាដំណោះស្រាយដែលគ្មានមូលដ្ឋានច្បាប់នីតិវិធី អ.វ.ត.ក ត្រូវចាត់ទុកជាមោឃៈ។

១៥. ការបកស្រាយបទប្បញ្ញត្តិវិធាន ៦៧(២) ស្តីពីមោឃភាពនៃដីកាដំណោះស្រាយដែលមានវិការៈនីតិវិធី រួមទាំង *ចន្លោះប្រហោង* នៅក្នុងនោះ ត្រូវអនុវត្តស្របតាមវិធានបកស្រាយនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡ។ យោងតាមអង្គជំនុំជម្រះតុលាការកំពូល វិធានបកស្រាយទាំងនេះ “ធ្វើការពិចារណាលើពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលការណ៍”[27]។

១៦. ក្រៅពីវិធាន ៦៧(២) ក្របខណ្ឌច្បាប់ អ.វ.ត.ក ពុំមានវិធាន ឬ គោលការណ៍ជាក់លាក់ផ្សេងទៀតសម្រាប់ធ្វើមោឃភាពដីកាដំណោះស្រាយនោះទេ។ ដើម្បីបកស្រាយវិធាន ៦៧(២) ឲ្យបានត្រឹមត្រូវនៅក្នុង “ប្រព័ន្ធ” នៃមោឃភាពក្នុងកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលមុនអង្គជំនុំជម្រះរបស់ អ.វ.ត.ក វិធាននេះត្រូវអនុវត្តក្នុងបរិបទនៃបទប្បញ្ញត្តិវិធាន ៧៦ ស្តីពីមោឃភាពនៅក្នុងអំឡុងកិច្ចស៊ើបសួរ។ អនុលោមតាមវិធាន ៧៦(១) ស.ច.ស ត្រូវជូនដំណឹងភាគីអំពីផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីដែលខ្លួនយល់ឃើញថាត្រូវចាត់ទុកជាមោឃៈ។ វិធាន ៧៦(២) ផ្តល់សិទ្ធិដល់ភាគីដាក់សំណើសុំមោឃភាពជូនទៅ ស.ច.ស នៅមុនពេលបិទកិច្ចស៊ើបសួរ និងស្នើសុំឲ្យ ស.ច.ស ប្តឹងទៅ អ.ប.ជ។ វិធាន ៧៦(៧) ចែងថា វិការៈនីតិវិធីនៅក្នុងការស៊ើបអង្កេតនឹងអាចជួសជុលបានតាមរយៈដីកាដំណោះស្រាយ ហើយការជួសជុលវិការៈផ្នែកនីតិវិធីដោយដីកាដំណោះស្រាយ “បើកផ្លូវឲ្យប្តឹងតវ៉ា”។ អ្នកធ្វើសេចក្តីព្រាងវិធាន ៧៦ បានបង្កើតយន្តការមោឃភាពទាំងនេះ ខណៈបានគិតគូរថា មោឃភាពនៅដំណាក់កាលមុនអង្គសេចក្តី នឹងធ្វើឡើងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរតែប៉ុណ្ណោះ ពុំមែននៅដំណាក់កាលបន្ទាប់នោះទេ។ អ្នកធ្វើសេចក្តីព្រាងទំនងមិនអាចប្រមើលមើលឃើញអំពីភាពចាំបាច់តម្រូវឲ្យនីតិវិធីមួយជំទាស់លើមូលដ្ឋានច្បាប់នៃការចេញដីកា

[27] សំណុំរឿង ០០៤/១ *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

ដំណោះស្រាយរបស់ខ្លួននោះទេ[28]។

១៧. ដើម្បីបកស្រាយវិធាន ៧៦(២) ឱ្យបានត្រឹមត្រូវ ខ្លឹមសារនៃវិធាន ៧៦ គាំទ្រថា *គោលការណ៍ចម្បង និងគោលដៅសំខាន់នៃប្រព័ន្ធ* មោឃភាពនៅមុនការជំនុំជម្រះ គឺដើម្បីធានាថា កិច្ច ឬដីកាបង្គាប់ ដែលមានវិការៈផ្នែកនីតិវិធីរបស់ ស.ច.ស បើកផ្លូវឱ្យ អ.ប.ជ មោឃភាព។ នៅក្នុងវិធាន ៧៦(៥) ទាំងសំណៅជាភាសាអង់គ្លេស និងបារាំង ពាក្យដូចគ្នាសម្រាប់ "មោឃភាព" និង "ការលុបចោល" ត្រូវបានយកមកប្រើប្រាស់ជំនួសគ្នា[29]។ នៅក្នុងភាសាបារាំង ពាក្យ "មោឃៈ" មានន័យថា "បដិសេធចោល ប្រកាសថាមោឃៈ"[30] ចំពោះ "ការលុបចោល" មានន័យដូចគ្នា និង "មោឃកម្ម" មានន័យថា "លុបចោលកិច្ចទាំងឡាយដែលបានបង្ហាញជាលាយលក្ខណ៍អក្សរ"[31]។

---

[28] តាមពិតទៅ យោបល់តាមផ្លូវតុលាការនៅ អ.ប.ជ នៃ អ.វ.ត.ក បានទទួលស្គាល់ថា កិច្ចដែលបានបំពេញទាក់ទងនឹងនីតិវិធីដែលមិនត្រូវបានអនុញ្ញាត៖ 'ការជំនុំជម្រះដោយយុត្តិធម៌ ឬការពិចារណាទៅលើបញ្ហាមួយនឹងត្រូវពាក់ព័ន្ធ [*sic*] មិនមែនត្រឹមតែសិទ្ធិដែលត្រូវដឹងអំពីសំណុំរឿងដែលខ្លួនត្រូវឆ្លើយ និងសិទ្ធិទទួលបានការជំនុំជម្រះប៉ុណ្ណោះទេ តែក៏ត្រូវមានសិទ្ធិទទួលបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីផងដែរ។ ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ក្នុងន័យនេះ នឹងត្រូវរាប់បញ្ចូលនូវនីតិវិធីប្រកបដោយតម្លាភាព និងដែលត្រូវបានអនុញ្ញាត ក្នុងករណីដែលសិទ្ធិ និងកាតព្វកិច្ចត្រូវបានចែង ត្រូវបានបញ្ជាក់ និងត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។ តាមមធ្យោបាយនេះ វាមានសច្ចភាពដោយការរំពឹងថា បញ្ហាមួយនឹងត្រូវបានដោះស្រាយតាមរបៀបមួយដោយអាចព្យាករណ៍បាន ត្រឹមត្រូវ និងកំណត់ន័យច្បាស់លាស់។ វាមិនមែនសម្រាប់ឱ្យតុលាការ ឬចៅក្រមដែលមិនមានការអនុញ្ញាត ត្រូវកែប្រែនីតិវិធីដែលត្រូវបានបញ្ជាក់ច្បាស់លាស់រួចហើយ ថាជាភាពត្រឹមត្រូវ ឬសម្រាប់ហេតុផលណាមួយដែលមិនត្រូវបានអនុញ្ញាតនោះទេ។ នេះជាភាពមិនត្រឹមត្រូវតាមនីតិវិធីនោះឡើយ។ កិច្ចណាមួយធ្វើឡើងទាក់ទងនឹងនីតិវិធីដែលមិនត្រូវបានអនុញ្ញាតបែបនេះត្រូវចាត់ទុកជាមោឃៈ'។ សំណុំរឿង ០០២ *សាលដីកាលើបណ្តឹងឧទ្ធរណ៍ លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧* ឯកសារ D250/3/2/1/5 មតិយោបល់របស់ចៅក្រម ប្រាក់ គឹម សាន និងចៅក្រម Rowan Downing ទាក់ទងនឹងសេចក្តីប្រកាសអំពីភាពមិនអាចទទួលយកបាននូវដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់រួចមកហើយ កថាខណ្ឌ ១៣។

[29] អត្ថបទជាភាសាបារាំងនៃវិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង និយាយអំពី 'les parties annulées sont cancellées' and '[a]près annulation ou cancellation, […]'។

[30] F.H.S. Bridge *ក្រុមប្រឹក្សាវចនានុក្រមច្បាប់-បារាំងអង់គ្លេស* ក្រុមប្រឹក្សាអឺរ៉ុបផ្នែកបោះពុម្ពផ្សាយ ឆ្នាំ១៩៩៤ ទំព័រ ១៦។

[31] អនុលោមតាមសេចក្តីអត្ថាធិប្បាយរបស់សាស្ត្រាចារ្យ Jean-Paul Doucet ពាក្យថា *ការលុបចោល* ត្រូវបានកំណត់និយមន័យជាកិរិយាសព្ទក្នុងភាសាបារាំងថា *biffe*៖ 'CANCELLATION (Canceller): Cf. Abolition, Nullité. Du latin "cancellare": biffer. Terme juridique visant le fait d'annuler un acte juridique d'une manière matérielle : en le biffant, en le raturant ou en le lacérant.' *Dictionnaire de Droit Criminel*, 'Cancellation,' *ដែលអាចរកឃើញនៅលើគេហទំព័រ* https://ledroitcriminel.fr/dictionnaire/lettre_c/lettre_c_can.htm (ទទួលបានចុងក្រោយនៅថ្ងៃទី១៨ ខែ

អនុលោមតាមវិធាន ៧៦(៥) អំពើវិការៈនីតិវិធីដែលត្រូវបានមោឃៈ ឬ លុបចោល ពុំមានអត្ថិភាពទៀតទេ គឺ វាត្រូវបាន *ដកចេញ* ពីក្នុងសំណុំរឿង ហើយត្រូវបានហាមឃាត់មិនឱ្យទាញសេចក្តីសន្និដ្ឋានពីករណីនេះប្រឆាំងនឹងភាគីនោះឡើយ[32]។ នីតិវិធីមោឃភាពឃើញមានចែងដូចគ្នានៅក្នុងមាត្រា ២៨០ មាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ១៧៤ មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង[33]។

១៨. ការលើកឡើងថា ដីកាដំណោះស្រាយដែលចេញដោយខុសច្បាប់មានវិការៈនីតិវិធីនៅក្នុងអត្ថន័យនៃវិធាន ៦៧(២) មានមូលដ្ឋានគាំទ្របន្ថែមនៅក្នុងយុត្តាធិការជាតិ និងអន្តរជាតិ។ អ.ប.ជ បានអនុវត្តវិធីសាស្ត្របកស្រាយមួយ ដែលក្នុងនោះ ក្រោយអនុវត្តស្តង់ដារវិធានបកស្រាយចំពោះក្របខ័ណ្ឌច្បាប់ អ.វ.ត.ក អ.ប.ជ នឹងពិនិត្យមើលនីតិវិធីកម្ពុជា បន្ទាប់មកនីតិវិធីនៅកម្រិតអន្តរជាតិ[34]។

---

កុម្ភៈ ឆ្នាំ២០២០)។ វនានុក្រមភាសាបារាំងដែលអាចរកបានជាសាធារណៈ កំណត់និយមន័យពាក្យ *cancellation* ថា៖ ‘Fait d’annuler un acte en effaçant ce qui est écrit. Signifie également “annulation”.’ Linternaute, Dictionnaire Française, ‘Cancellation,’ *ដែលអាចរកឃើញនៅលើគេហទំព័រ* https://www.linternaute.fr/dictionnaire/fr/definition /cancellation/ (ទទួលបានចុងក្រោយនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០)។

[32] អ.ប.ជ បានបង្គាប់ឱ្យ “លុបចោល និងដកចេញ” ពីសំណុំរឿងនូវផ្នែកដែលមានកំហុសនីតិវិធីក្នុងកំណត់ហេតុនៃកិច្ចស៊ើបសួរ នៅក្នុង*សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ Paolo Stocchi* ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ៣៦ និងទំព័រ ១៧។

[33] ក្រមនីតិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៨១៖ “ក្រោយពីធ្វើមោឃកម្មរួចមក សភាស៊ើបសួរអាច៖ បង្វិកទៅសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ។ ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ទៀត ឬន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនោះ”។ ក្រមនីតិធីព្រហ្មទណ្ឌបារាំង មាត្រា ២០៦៖ “ក្រោយពីធ្វើមោឃកម្មរួចមក [សភាស៊ើបសួរ] អាចបញ្ជូនសំណុំរឿងមកឱ្យខ្លួនឯង និងបន្តដំណើរនីតិវិធីស្របតាមលក្ខខណ្ឌដូចមានចែងក្នុង ២០១, ២០២ និង ២០៤ ឬបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរដដែលឡើងវិញ ឬទៅចៅក្រមស៊ើបសួរម្នាក់ទៀតដើម្បីបន្តកិច្ចស៊ើបសួរ”។ [ការបកប្រែដោយ Légifrance]។ *សូមមើល ផងដែរ* ក្រមនីតិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៨០។ ក្រមនីតិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៤។

[34] អ.ប.ជ បានសម្រេចថា វិធានផ្ទៃក្នុង គឺជាប្រភពចម្បងនៃច្បាប់ស្តីពីដំណើរនីតិវិធីនៅ អ.វ.ត.ក ហើយក្រមនីតិធីព្រហ្មទណ្ឌកម្ពុជាគួរយកមកអនុវត្ត ក្នុងករណីមានបញ្ហាចោទណាមួយដែលវិធានផ្ទៃក្នុងមិនមានចែងតែប៉ុណ្ណោះ”។ សំណុំរឿង ០០២ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព* ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៤ ដល់ ១៥។ ក្នុងករណីដែលក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា “ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ” នោះអង្គជំនុំជម្រះអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ *សូមមើល* កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក មាត្រា ១២(១)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា

១៩. នៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិល្សក្រៅពីប្រទេសបារាំង និងកម្ពុជា ច្បាប់ចែងថា ដីកាដែលចេញដោយខុសច្បាប់ ត្រូវចាត់ទុកជាមោឃៈ ហើយវាគ្មានតម្លៃ និងអានុភាពគតិយុត្តិឡើយ។ ឧទាហរណ៍ នៅសាធារណរដ្ឋកូរ៉េ “បណ្តឹងអាជ្ញាត្រូវច្រានចោលតាមអំណាចសាលក្រម [...] នៅពេលនីតិវិធីធ្វើបណ្តឹងអាជ្ញាមោឃៈដោយសារវាផ្ទុយនឹងបទប្បញ្ញត្តិច្បាប់”[35]។ តាមឧទាហរណ៍មួយទៀត នៅប្រទេសលីប៊ី មោឃភាពអាចធ្វើទៅបានដោយសារការមិនគោរពច្បាប់ និងនៅពេលនីតិវិធីត្រូវបានចាត់ទុកថាគ្មានសុពលភាព “អានុភាពកើតចេញដោយផ្ទាល់ពីនីតិវិធីនេះដូចគ្នា”[36]។

២០. យោងតាមការវិភាគរបស់មេធាវីការពារក្តីនៃយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិល ច្បាស់ណាស់ថាគោលការណ៍ដែលថា ដីកាចេញដោយខុសច្បាប់ត្រូវចាត់ទុកជាមោឃៈ ហើយផលវិបាកគឺវាពុំមានអានុភាពផ្លូវច្បាប់ ហើយ*នរណាៗក៏គេដឹង* គោលការណ៍នេះល្បី និងគេដឹងឮទូទៅរួចហើយ ហើយក៏កម្រមានការជំទាស់ដែរ។ អ្វីដែលជៀសមិនរួច យុត្តិសាស្ត្រដែលចៅក្រមពិចារណាលើអត្ថន័យនៃគោលការណ៍នេះគឺស្ទើរតែគ្មាន ឬ មិនមានតែម្តង[37]។

---

៣៣ថ្មី។ វិធាន ២ នៃវិធានផ្ទៃក្នុង។ *សូមមើល ផងដែរ* សំណុំរឿង ០០២/០១ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៨ ដល់ ១២៦។ អ.ប.ជ បានពិចារណាទៅលើការបកស្រាយត្រឹមត្រូវនូវពាក្យ “សម្រេចឲ្យរួចខ្លួន” នៅក្នុងមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ អ.ប.ជ បានលើកឡើងពី “គោលការណ៍នៃការបកស្រាយដែលគេបានទទួលស្គាល់” ទាក់ទងនឹងការបង្កើតច្បាប់លក្ខន្តិកៈ និងលិខិតុបករណ៍លាយលក្ខណ៍អក្សរទាំងអស់ ដោយលើកឡើងថា “ត្រូវប្រកាន់ខ្ជាប់អត្ថន័យតាមវាយ្យករណ៍ និងតាមន័យធម្មតា លើកលែងតែថា វាអាចនាំឲ្យមានភាពមិនសមហេតុផល ឬភាពមិនស៊ីសង្វាក់គ្នាជាមួយលិខិតុបករណ៍នោះ”។ នៅក្នុងកថាខណ្ឌ ១១៨ អ.ប.ជ បានកត់សម្គាល់ឃើញថា កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង មិនមានចែងអំពីការហាមឃាត់ចំពោះការកាត់ទោសពីរដង និងមិនបាននិយាយអានុភាពនៃការផ្តន្ទាទោសពីមុន ទៅលើនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នោះទេ និងសម្រេចថា “អនុលោមតាមមាត្រា ១២ នៃកិច្ចព្រមព្រៀង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ៣៣ *ថ្មី*ច្បាប់បង្កើត អ.វ.ត.ក អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលក្រមនីតិវិធីព្រហ្មទណ្ឌ [...]”។ អ.ប.ជ បានបន្តពិនិត្យមើលនីតិវិធីព្រហ្មទណ្ឌកម្ពុជានៅក្នុងកថាខណ្ឌ ១១៩ ដល់ ១២៤ ដោយសម្រេចថា តាមន័យធម្មតានៃមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនអនុវត្តចំពោះទណ្ឌិតនោះទេ។ អ.ប.ជ បានពឹងផ្អែកទៅលើការស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

[35] សាធារណរដ្ឋកូរ៉េ ច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់លេខ ៩៧៦៥ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ មាត្រា ៣២៧(២)។

[36] ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសលីប៊ី និងច្បាប់បំពេញបន្ថែមនានា ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មាត្រា ៣០៤ និង ៣០៩។

[37] ទោះបីជាមានវិរិយភាព និងការខិតខំប្រឹងប្រែងដ៏ប្រសើរបំផុតពីសំណាក់មេធាវីការពារក្តី ដើម្បីស្វែងរកយុត្តិសាស្ត្រពីយុត្តាធិការច្បាប់ស៊ីវិល ទៅលើផលវិបាលនៃសេចក្តីសម្រេចខុសច្បាប់នានាយ៉ាងណាក៏ដោយ ក៏មេធាវីការពារក្តីមិនអាចរកឃើញពី

២១. នៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ខំមិនឡូ គេក៏ចាត់ទុកជាគោលការណ៍ទូទៅដូចគ្នា។ ទោះបីជាគោលការណ៍ដែលចែងថា សេចក្តីសម្រេចតុលាការដែលខុសច្បាប់ត្រូវចាត់ទុកជា "មោឃៈ" ហើយមិនមានអានុភាពផ្លូវច្បាប់ តែងតែត្រូវបានលើកឡើងនៅក្នុងយុត្តិសាស្ត្រក៏ដោយ ក៏គេកម្រជំទាស់ណាស់។ ឧទាហរណ៍ នៅក្នុងយុត្តិសាស្ត្រសហរដ្ឋអាមេរិក "អានុភាពនៃការសម្រេចថា សាលក្រមមួយមិនយកជាការ ត្រូវបានកំណត់យ៉ាងច្បាស់។ យ៉ាងណាក៏ដោយ នីតិវិធីនេះមិន ដែលបានកើតឡើងឡើយ។ សាលក្រមនេះមិនមានសុពលភាពទេ ហើយភាគីស្ថិតក្នុងស្ថានភាព ដូចគ្នាដូចជាថាគ្មានសាលក្រមនោះទេ"[38]។ គោលការណ៍ច្បាស់មួយគឺថា តុលាការកំពូលផ្នែកព្រហ្មទណ្ឌនៅតិចសាសដែលបានសម្រេចលើរឿងក្តី *Seidel* ដែលពុំមែនជាភាគីនៃរឿងក្តី។ នៅក្នុងសេចក្តីសម្រេចនោះ ការលើកលែងការចោទប្រកាន់ "ជាអចិន្ត្រៃយ៍" ត្រូវបានចាត់ទុកថា "មានលក្ខណៈផ្សេងទៀតពីទង្វើធម្មតា។ អំពើនោះនៅក្រៅវិសាលភាពដែនកំណត់នៃវិធាន ឬ នីតិវិធីជាធរមាននាពេលនោះ"[39]។ តុលាការបានសន្និដ្ឋានថា "កិច្ចរបស់ចៅក្រមជំនុំជម្រះគ្មានអ្វីក្រៅពីការរំលោភបំពានលក្ខន្តិកៈនីតិវិធី" ហើយ "កិច្ចរបស់ចៅក្រមជំនុំជម្រះត្រូវបានច្បាប់អនុញ្ញាត

---

ប្រភពដែលខ្លួនមានបានដែរ គឺឯកសារយោងនៅក្នុងសេចក្តសម្រេចនានារបស់តុលាការ ដែលធ្វើការពន្យល់អំពីផលវិបាកតាមផ្លូវច្បាប់ចំពោះដីកាសម្រេចដែលបានចេញខុសច្បាប់នេះដែរ។

[38] រឿងក្តីរវាង *Romito* ទល់នឹង *Maxwell*, 227 N.E.2d, 223, 224 (រដ្ឋអូហាយ៉ូ ឆ្នាំ១៩៦៧)៖ "អានុភាពនៃការពិចារណាថា សាលក្រមមួយមានមោឃភាព ត្រូវបានកំណត់យ៉ាងច្បាស់។ ហេតុដូច្នេះហើយ នីតិវិធីបែបនេះមិនធ្លាប់កើតមាននោះឡើយ។ សាលក្រមនេះ គឺគ្រាន់តែជាសាលក្រមមោឃៈប៉ុណ្ណោះ ហើយភាគីក៏មានជំហរដូចគ្នា ដោយចាត់ទុកថាពុំមានសាលក្រមនោះឡើយ (សេចក្តីយោងខាងក្នុងត្រូវបាលុបចោល)។ ការលុបចោលការផ្តន្ទាទោសពីមុនចំពោះបទល្មើសលបលួចចូល នៅក្នុងករណីនេះ គឺជាផ្នែកសំខាន់មួយនៃកិច្ចដំណើរការនីតិវិធីតាមទម្លាប់ ហើយនៅពេលដែលកិច្ចដំណើរការនីតិវិធីតាមទម្លាប់បែបនេះត្រូវបានប្រកាសជាមោឃៈ នោះការលុបចោលការផ្តន្ទាទោសពីមុនចំពោះបទល្មើសលបលួចចូល ក៏ត្រូវបានចាត់ទុកជាមោឃៈដែរ។ ម្ចាស់បណ្តឹងក៏ស្ថិតនៅក្នុងជំហរដូចគ្នា នៅក្រោមការផ្តន្ទាទោសដែលមានសុពលភាពសម្រាប់បទល្មើសលបលួចចូល" ។ *សូមមើល ផងដែរ* រឿងក្តីរវាង *រដ្ឋ ទល់នឹង Bezak*, 868 N.E.2d 961, 963 (រដ្ឋអូហាយ៉ូ ឆ្នាំ២០០៧) ដែលដកស្រង់រឿងក្តីរវាង *Romito* ទល់នឹង *Maxwe*៖ "នៅក្នុងករណីនេះ Bezak ពុំបានទទួលដំណឹងអំពីការកំណត់ការត្រួតពិនិត្យលើការដោះលែងជាក្រោយ នៅក្នុងការជំនុំជម្រះផ្តន្ទាទោសមកលើរូបគាត់។ ជាលទ្ធផល ការផ្តន្ទាទោសដែលបានកំណត់ដោយតុលាការនេះត្រូវចាត់ទុកជាមោឃៈ។ "អានុភាពនៃការពិចារណាថា សាលក្រមមួយមានមោឃភាព ត្រូវបានកំណត់យ៉ាងច្បាស់។ ហេតុដូច្នេះហើយ នីតិវិធីបែបនេះមិនធ្លាប់កើតមាននោះទេ។ សាលក្រមនេះ គឺគ្រាន់តែជាសាលក្រមមោឃៈប៉ុណ្ណោះ ហើយភាគីក៏មានជំហរដូចគ្នា ដោយចាត់ទុកថាពុំមានសាលក្រមនោះឡើយ"។ *សូមមើល ផងដែរ Ex parte Seidel*, 39 S.W.3d 221, 225 (Tex. Crim. App. 2001)។

[39] រឿងក្តី *Ex parte Seidel*, 39 S.W.3d 221, 225 (Tex. Crim. App. 2001)។

ហេតុដូច្នេះ ត្រូវចាត់ទុកជាមោឃៈ"[40]។ តុលាការបានសម្រេចថា៖

សាលក្រមដែលគ្មានសុពលភាព ត្រូវមោឃៈភាព តាំងពីដើម ហើយពុំមានផលវិបាកដូចសាលក្រមដែលមានសុពលភាពឡើយ។ សាលក្រមបែបនេះពុំត្រូវបានគោរពដោយសារវាពុំប៉ះពាល់បង្កព្យសនកម្ម ឬបង្កើតសិទ្ធិតាមផ្លូវច្បាប់ឡើយ[41]។

២២. នៅក្នុងរឿងក្តី *រដ្ឋ ទល់នឹង Simpkins* តុលាការកំពូលនៃរដ្ឋ Ohio បានបែងចែករវាងកិច្ចតុលាការដែលអាចមោឃៈបាន ដោយសារកំហុសអង្គច្បាប់ និងកិច្ចតុលាការខុសច្បាប់ទាំងស្រុង ដែលត្រូវមោឃៈជាដាច់ខាត៖

នៅក្នុងកាលៈទេសៈដែលចៅក្រមមិនអនុវត្តច្បាប់ដែលបង្គាប់ជាក់លាក់លើកិច្ចណាមួយ ដូចជានៅពេលចៅក្រមមិនប្រើឆន្ទានុសិទ្ធិដាក់ទណ្ឌកម្មណាមួយ ដែលច្បាប់កំណត់ទោសតម្រូវ ចៅក្រមបំពេញកិច្ចដោយពុំមានសិទ្ធិអំណាច។ កិច្ចបែបនោះពុំមែនត្រឹមតែជាកំហុសដែលអាចឲ្យមោឃៈទោសនោះទេ វាត្រូវមោឃៈដាច់ខាត។ ប្រសិនបើចៅក្រមកំណត់ទោសដែលច្បាប់ពុំអនុញ្ញាតវាជាការដាក់ទោសខុសច្បាប់។ "ប្រសិនបើអំពើមួយខុសច្បាប់ វាពុំមែនជាកំហុស ឬ អាចមោឃៈបាននោះទេ ប៉ុន្តែវាពុំអនុញ្ញាតតែម្តង និងមោឃៈជាដាច់ខាត"[42]។

២៣. តុលាការកំពូលនៃចក្រភពអង់គ្លេសថ្មីៗនេះបានតម្កល់គោលការណ៍ដូចគ្នានៅក្នុងរឿងក្តី *R ទល់នឹង Miller* នៅក្នុងបរិបទនៃការផ្តល់យោបល់ខុសច្បាប់ ដោយនាយករដ្ឋមន្ត្រី ជូនទៅព្រះមហាក្សត្រយានី ដែលសភាគួរទុកចោលមិនពិចារណា៖

នេះមានន័យថា ករណីនេះគ្មានសុពលភាព និងគ្មានអានុភាពអនុវត្ត [...]។ នាំឲ្យមានការបង្គាប់នៅក្នុងក្រុមប្រឹក្សា ដែលនៅពេលបង្កើតឡើងផ្អែកលើយោបល់ខុសច្បាប់ ក៏ខុសច្បាប់ដូចគ្នា គ្មានអានុភាពអនុវត្ត ហើយត្រូវប្រានចោល។ ជាក់ស្តែង ករណីនេះនាំឲ្យមានការទុកចោលមិនពិចារណា ដែលវាហាក់ដូចជាស្នងការទាំងឡាយចូលទៅក្នុងសភាដោយមានក្រដាសសមួយ

---

[40] *ដូចខាងលើ*។

[41] *ដូចខាងលើ* ដកស្រង់ពីរឿងក្តី *Ex parte Spaulding*, 687 S.W.2d 741, 745 (Teague, J., ស្របគ្នា)។

[42] រឿងក្តីរវាង *រដ្ឋ ទល់នឹង* *Simpkins*, 884 N.E. 2d 568, 575 (រដ្ឋអូហាយ៉ូ ឆ្នាំ២០០៨) (សេចក្តីយោងខាងក្នុងត្រូវបានលុបចោល)។

សន្តឹក។ វាក៏ខុសច្បាស់ គ្មានសុពលភាព និងគ្មានអានុភាពអនុវត្ត[43]។

២៤. យុត្តិសាស្ត្ររបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ថា ដីកាសម្រេច ឬ កិច្ចខុសច្បាប់ គឺ អ្វីៗដែលផ្ទុយនឹងច្បាប់ និងនីតិវិធីជាធរមាន ត្រូវចាត់ទុកជាមោឃៈ និងគ្មានអានុភាពផ្លូវច្បាប់ទេ។ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តី ICTR នៅក្នុងរឿងក្តី *Ntuyahaga* បានសម្រេចថា ឯកសារ "កិច្ចប្រកបដោយសុវត្ថិភាព" របស់ក្រឡាបញ្ជី/រដ្ឋបាល ត្រូវបានប្រគល់ជូនទៅជនជាប់ចោទ ក្រោយពេលការដោះលែងគាត់ត្រូវបានចាត់ទុកជា "មោឃៈ" ដោយសារ "បទប្បញ្ញត្តិនៃសេចក្តីសម្រេចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ និងបទប្បញ្ញត្តិនៃច្បាប់លក្ខន្តិកៈ វិធាននីតិវិធី និងភស្តុតាង ឬការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង បានប្រគល់សិទ្ធិអំណាចឲ្យក្រឡាបញ្ជី/រដ្ឋបាល ចេញឯកសារចំណងជើងថា "កិច្ចប្រកបដោយសុវត្ថិភាព"[44]។ អង្គជំនុំជម្រះសាលាដំបូង "បានដឹងអំពីតម្រូវការរបស់សាលាក្តីដើម្បីធានានូវការគោរព និងអនុលោមភាពនៃច្បាប់ ឲ្យបានត្រឹមត្រូវ"[45]។

២៥. អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY បានសម្រេចនៅក្នុងរឿងក្តី *Kupreškić និង អ្នកផ្សេងទៀត* ថា ដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទទួលយកសេចក្តីថ្លែងរបស់សាក្សីដោះបន្ទុក ត្រូវចាត់ទុកជា "មោឃៈ" ដោយសារតែខកខានមិនបានគោរពតាមលក្ខខណ្ឌតម្រូវនៅក្នុង

---

[43] R *(ស្តីពីពាក្យបណ្តឹងរបស់ Miller) (ដើមបណ្តឹង) ទល់នឹង នាយករដ្ឋមន្ត្រី (ចុងចម្លើយ) Cherry និងចុងចម្លើយផ្សេងទៀត ទល់នឹង អគ្គមេធាវីប្រទេសស្កុតឡែន (ដើមបណ្តឹង) (ប្រទេសស្កុតឡែន)* [ឆ្នាំ ២០១៩] UKSC 41, កថាខណ្ឌ ៦៩។ *សូមមើលផងដែរ (ស្តីពីពាក្យបណ្តឹងរបស់ UNISON) (ដើមបណ្តឹង) ទល់នឹង Lord Chancellor (ចុងចម្លើយ),* [ឆ្នាំ ២០១៧] UKSC 51, កថាខណ្ឌ ១១៩ "សេចក្តីសម្រេចលើប្រាក់ប្រដាប់ក្តីនេះ គឺផ្ទុយទាំងច្បាប់ក្នុងស្រុក និងច្បាប់របស់សហគមន៍អឺរ៉ុប ពីព្រោះវាមានអានុភាពរារាំងដល់ការទទួលបានយុត្តិធម៌។ ដោយសារវាមានផលប៉ះពាល់ភ្លាមៗបន្ទាប់ពីការសម្រេច ដូច្នេះសេចក្តីសម្រេចនេះខុសច្បាប់តាំងពីដើមដំបូង (ab initio) និងត្រូវតែបដិសេធចោល"។

[44] អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR រឿងក្តីរវាង *Prosecutor ទល់នឹង Ntuyahaga* (ICTR-98-40-T) "សេចក្តីប្រកាសអំពីចំណុចច្បាប់" ចុះថ្ងៃទី២២ ខែ មេសា ឆ្នាំ១៩៩៩ កថាខណ្ឌ ១, ៤ និង ១៧។ មន្ត្រីគ្រប់គ្រងឯកសារបានចេញឯកសារមួយឈ្មោះ "ទង្វើប្រកបដោយសុវត្ថិភាព" ដោយការស្នើសុំឲ្យរដ្ឋជាសមាជិកនៃ អ.ស.ប អង្គការអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធដទៃទៀតផ្តល់ជូននូវកិច្ចសហការចាំបាច់ដល់ចុងចោទ ដើម្បីបង្កលក្ខណៈឲ្យគេ "ធ្វើដំណើរដោយសេរី នៅក្នុង ឬឆ្លងកាត់ ដោយពុំមានឧបសគ្គ ឬការរារាំង នៅក្នុងប្រទេសណាមួយរហូតដល់គោលដៅចុងក្រោយរបស់គេ"។ មេធាវីការពារក្តីបានខិតខំប្រឹងប្រែងដើម្បីស្នើសុំអត្តបទដើមនៃសេចក្តីសម្រេចនេះ ប៉ុន្តែ សេចក្តីសម្រេចនេះកំពុងស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវច្បាប់ពីសំណាក់ ICTR (MICT) ដើម្បីពិចារណាអំពីការធ្វើចំណាត់ថ្នាក់របស់ឯកសារនេះ និងមិនអាចរកបានជាសាធារណៈឡើយ។

[45] *ដូចខាងលើ* កថាខណ្ឌ ១៧។

លក្ខន្តិកៈ និងវិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY[46]។ ចៅក្រមប្រធានអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា ចៅក្រមជំនុំជម្រះមួយរូបមានជំងឺ និងទំនងពុំអាចចូលរួមសវនាការពេញមួយសប្តាហ៍[47]។ បន្ទាប់មក គាត់បានចេញសេចក្តីសម្រេចផ្ទាល់មាត់ថា វិធាន ៧១ នៃវិធាននីតិវិធី និងភ័ស្តុតាង អាចអនុវត្តបាន ហើយចម្លើយរបស់សាក្សីដោះបន្ទុកត្រូវបានធ្វើឡើងជាមួយចៅក្រមពីររូបដែលមានវត្តមាន បំពេញការងារជាប្រធានដឹកនាំ[48]។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដោយតម្កល់ដីកាសម្រេចផ្ទាល់មាត់នៅថ្ងៃបន្ទាប់[49]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "លក្ខខណ្ឌនៅក្នុងវិធាន ៧១ ចែងថា ដីកាសម្រេចលើស្តាប់ចម្លើយសាក្សី អាចធ្វើឡើងដោយអង្គជំនុំជម្រះ ពុំត្រូវបានបំពេញនោះទេ" ដោយសារមាត្រា ១២ នៃលក្ខន្តិកៈរបស់សាលាក្តី ICTY ចែងថា អង្គជំនុំជម្រះសាលាដំបូងត្រូវមានចៅក្រម ០៣ រូប[50]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ការតម្កល់ជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះដីកាសម្រេចផ្ទាល់មាត់ "មិនអាចជួសជុលអំពើខុសច្បាប់ជាក់លាក់នោះទេ"[51]។

២៦. ការបកស្រាយត្រឹមត្រូវលើវិធាន ៦៧(២) ដែលថា ការពិចារណាលើឋានៈនៃវិធាននេះ នៅក្នុង

---

[46] អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការ *រដ្ឋអាជ្ញា ទល់នឹង Kupreškić និងជនជាប់ចោទផ្សេងទៀត* (IT-95-16-AR73.3), ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Dragan Papić ប្រឆាំងនឹងការសម្រេចដំណើរការនីតិវិធីដោយការឲ្យសាក្សីធ្វើសម្បថ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៤។

[47] *ដូចខាងលើ* កថាខណ្ឌ ៤។

[48] *ដូចខាងលើ* កថាខណ្ឌ ៦ និង ៧។

[49] *ដូចខាងលើ* កថាខណ្ឌ ៧។

[50] *ដូចខាងលើ* កថាខណ្ឌ ១៤។

[51] *ដូចខាងលើ* កថាខណ្ឌ ១៤។ "ក្នុងករណីដែលច្បាប់លក្ខន្តិកៈ ឬវិធានចែងថា បញ្ហាមួយត្រូវសម្រេចដោយ*អង្គជំនុំជម្រះសាលាដំបូង* នោះចៅក្រមសម្រេចសេចក្តីពីរនាក់អាចនឹងមិនចូលរួមសម្រេចសេចក្តីក្នុងនាមជាផ្នែកមួយនៃនៃអង្គជំនុំជម្រះសាលាដំបូងឡើយ លើកលែងតែករណីដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលការអនុញ្ញាតជាមុនពីប្រធានអង្គជំនុំជម្រះ។ ប៉ុន្តែ ការអនុញ្ញាតបែបនេះ អាចត្រូវបានផ្តល់ជូនចំពោះតែបញ្ហាជាទម្លាប់ ដោយអនុលោមតាមអនុវិធាន ១៥(ង)។ នៅក្នុងករណីបច្ចុប្បន្ននេះ ប្រធានអង្គជំនុំជម្រះពុំបានផ្តល់ការអនុញ្ញាតបែបនេះឡើយ ហើយក្នុងករណីណាក៏ដោយ ការចេញសេចក្តីសម្រេចណាមួយដើម្បីដំណើរការតាមមធ្យោបាយឲ្យសាក្សីធ្វើសម្បថ ទាក់ទងនឹងការសួរដេញដោលសាក្សីឲ្យផ្តល់ភ័ស្តុតាងលើអង្គហេតុទាំងឡាយដែលទាក់ទងនឹងបទចោទជាក់លាក់ ធ្វើឡើងប្រឆាំងនឹងជនជាប់ចោទ តាមរយៈការជំនុំជម្រះដោយផ្ទាល់ដើម្បីសម្រេចលើពិរុទ្ធភាព ឬការគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទ នោះតាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ មិនបង្កបានជា "បញ្ហាជាទម្លាប់" នៅក្នុងរង្វង់អត្ថន័យនៃអនុវិធាន ១៥(ង) ទេ (មានអក្សរទ្រេតបញ្ជាក់ក្នុងឯកសារដើម)។

ក្របខ័ណ្ឌគតិយុត្តិ រួមទាំង បរិបទនៃនីតិវិធីមោឃភាពនៅក្នុងវិធាន ៧៦ និងគោលការណ៍ ព្រមទាំងគោលដៅចម្បងសម្រាប់មោឃភាពនៅមុនការជំនុំជម្រះ តម្រូវថា អានុភាពនៃការ សម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤/០២ នោះ គឺថា ដីកាដំណោះស្រាយ ត្រូវចាត់ទុកជាមោឃៈ។ ចំណុចនេះបានទទួលការគាំទ្រដោយនីតិវិធីព្រហ្មទណ្ឌបារាំង និងកម្ពុជា និងទស្សនទាននៃ "មោឃកម្ម" ដែលមាននៅក្នុងយុត្តាធិការជាតិ និងអន្តរជាតិផ្សេងទៀត។ ការសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ គឺជាការសម្រេចលើវិការៈនីតិវិធី[52] ដែលមានផលវិបាកផ្នែកនីតិវិធីដូចគ្នា ដូចមានកំណត់នៅក្នុងវិធាន ៧៦(៥) ស្តីពី "មោឃភាព" ឬ "ការលុបចោល"[53]។ ដីកាដំណោះ

[52] វិធាន ៧៦(៥) ចែងថា កិច្ចស៊ើបសួរដែលត្រូវបានចាត់ទុកជាមោឃៈទាំងស់ និងឯកសារពាក់ព័ន្ធ "ត្រូវតែដកចេញពីសំណុំរឿង និងត្រូវតម្កល់ទុកដោយក្រឡាបញ្ជីរបស់ [អ.ប.ជ]។ បន្ទាប់ពីប្រកាសមោឃភាព ឬ ការលុបចោលនេះ [អ.ប.ជ] ត្រូវបញ្ជូនសំណុំរឿងត្រឡប់ទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញ"។ អ.ប.ជ សូមរំឭកថា សូម្បីតែ ស.ច.ស បានយល់ឃើញថា ការចេញដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នាបែបនេះ គឺផ្ទុយនឹងច្បាប់ហើយ ហើយពួកគាត់បានដឹងយ៉ាងច្បាស់ថា ភាពស្របច្បាប់នៃដីកាដំណោះស្រាយដាច់ពីគ្នា ជៀសមិនផុតពីការពិនិត្យពិច័យរបស់ អ.ប.ជ ទៅលើបណ្តឹងឧទ្ធរណ៍នោះទេ។ សេចក្តីពិចារណាលើសំណុំរឿង ០០៤/០២ កថាខណ្ឌ ១២៣៖ អ.ប.ជ បានកត់សម្គាល់ថា "ការប្រកាសយ៉ាងច្បាស់ដោយ ស.ច.ស [...] ថា ពួកគាត់បានឯកភាពគ្នាលើការចេញដោយខុសច្បាប់នូវដីកាដំណោះស្រាយដាច់ពីគ្នា ហើយផ្ទុយគ្នា"។ អ.ប.ជ យល់ឃើញជាឯកច្ឆ័ន្ទថា "ការអនុវត្តដោយខុសឆ្គងរបស់ ស.ច.ស នៅក្នុងករណីនេះ បង្កគ្រោះថ្នាក់ដល់ប្រព័ន្ធគតិយុត្តិទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ គួរឲ្យភ្ញាក់ផ្អើល ចៅក្រមស៊ើបអង្កេតបាន "ដឹងអំពីបញ្ហា" ដែលអាចកើតឡើងដោយសារតែការចេញដីកាដំណោះស្រាយដាច់ពីគ្នា ជាពិសេសនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍នោះ [...]"។

[53] ដូចដែល អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទរួចមកហើយថា "មិនដែលមានទាល់តែសោះនៅក្នុងប្រវត្តិសាស្ត្រជាតិ ឬ ប្រព័ន្ធច្បាប់អន្តរជាតិ ដែលសំណុំរឿងព្រហ្មទណ្ឌមួយ មានលក្ខណៈប្រហាក់ប្រហែលនឹងការចេញសេចក្តីសម្រេចពីរផ្ទុយគ្នា ក្នុងពេលតែមួយ ដោយអង្គភាពតុលាការមួយនោះ"។ សេចក្តីពិចារណារបស់ អ.ប.ជ លើសំណុំរឿង ០០៤/២ (អ.ប.ជ) ទំព័រ ១២៤។ ត្រូវប្រកាន់ខ្ជាប់ថា ទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ទាំងវិធាននីតិវិធី ដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ ពុំអាចដោះស្រាយកំហុសនីតិវិធីនៃដីកាដំណោះស្រាយពីរដែលបានចេញខុសច្បាប់បានទេ។ ប៉ុន្តែ វិធាន ២ និង ២១ នៃវិធានផ្ទៃក្នុងចែងអំពីគោលការណ៍ណែនាំលើការបកស្រាយថា ច្បាប់នីតិវិធីព្រហ្មទណ្ឌជាធរមានទាំងអស់ ត្រូវតែមកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ។ *សូមមើល* កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក មាត្រា ១២(១)។ ច្បាប់បង្កើត អ.វ.ត.ក មាត្រា ៣៣ *ថ្មី*។ វិធាន ២ និង ២១ នៃវិធានផ្ទៃក្នុង។ មធ្យោបាយតែមួយគត់ដើម្បីការពារប្រយោជន៍របស់លោក យឹម ទិត្យ គឺត្រូវបំពេញ ***ចន្លោះប្រហោង***នៅក្នុងវិធានផ្ទៃក្នុង និងអនុវត្តបទប្បញ្ញត្តិដោយការប្រៀបធៀប។ "ក្នុងករណីដែលអត្ថិភាពនៃភាពខ្វះចន្លោះត្រូវបានទទួលស្គាល់ នោះភារកិច្ចរបស់តុលាការ គឺត្រូវបំពេញចន្លោះប្រហោងទាំងនេះ ដោយប្រើប្រាស់បទប្បញ្ញត្តិច្បាប់ដែលកំណត់បញ្ហា ឬរឿងក្តីសំខាន់ៗដែលប្រដៀងគ្នា"។ [...] "ជួនកាល លក្ខន្តិកៈមួយនឹងគាំទ្រដល់លើប្រធានបទមួយទាំងស្រុង ប៉ុន្តែ "ករណីដែលមិនមានការអះអាង" នឹងកើតមានឡើង។ នៅត្រង់នេះ តុលាការអាចដោះស្រាយករណីនេះដោយលក្ខណៈប្រៀបធៀបទៅនឹងរបៀបនៃករណី "ដែលមានការអះអាង" ត្រូវបានអនុវត្តដោយក្នុងលក្ខន្តិកៈតែមួយ"។ Koszowski M.

ស្រាយដែលមានវិការៈនីតិវិធីត្រូវដកចេញពីក្នុងសំណុំរឿង និងពុំមានអានុភាពផ្លូវច្បាប់ទេ[54]។

---

"សំអាងហេតុដោយលក្ខណៈប្រៀបធៀបនៅក្នុងច្បាប់" (ឆ្នាំ២០១៧) *ទស្សនាវដ្ដី ស្រាវជ្រាវនីតិបច្ចេកវិទ្យា* (៨)១ ទំព័រ ១ ដែលដកស្រង់ Wróblewski J. "ការបកស្រាយច្បាប់នៅក្នុងប្រទេសប៉ូឡូញ" នៅក្នុង*ច្បាប់ស្ដីពីការបកស្រាយច្បាប់: ការសិក្សាប្រៀបធៀប,* Ashgate/Dartmouth, Aldershot, ឆ្នាំ១៩៩១ ទំព័រ ២៥៧ ដល់ ៣០៩ និង Summers, R "ការបកស្រាយច្បាប់នៅក្នុងសហរដ្ឋអាមេរិក" នៅក្នុង*ច្បាប់ស្ដីពីការបកស្រាយច្បាប់: ការសិក្សាប្រៀប ធៀប,* Ashgate/Dartmouth, Aldershot, ឆ្នាំ១៩៩១ ទំព័រ ៤០៧ ដល់ ៤៥៩។ *សូមមើល ផងដែរ* Koszowski M. "វិសាល ភាពនៃការអនុវត្តសំអាងហេតុដោយលក្ខណៈប្រៀបធៀបនៅក្នុងច្បាប់" (ឆ្នាំ២០១៧) *ទស្សនាវដ្ដីអន្តរជាតិជាមេរិកកាំងស្ដីពីការសិក្សាស្រាវជ្រាវសហកាល (៧) ១៦ ទំព័រ ១៧ និង ១៩៖* "ចន្លោះប្រហោងច្បាប់កើតមានឡើង នៅពេលដែលមិនមានវិធានច្បាប់ ដែលអាចយកមកអនុវត្តចំពោះករណីនៅក្នុងដៃបាន ទោះបីជាសង្គមចង់ឱ្យមានវិធានច្បាប់បែបនេះក្ដី ហើយករណីនៅចំពោះមុខត្រូវបានកំណត់ដើម្បី [...]។ ការបំពេញចន្លោះប្រហោងដោយការប្រើប្រាស់សំអាងហេតុបែបប្រៀបធៀបដូច្នេះ មាននៅក្នុងគោលការណ៍ក្នុងការស្វែងរកច្បាប់ដែលគ្របដណ្ដប់ទៅលើករណីនានាដែលមានលក្ខណៈស្រដៀងគ្នានឹងករណីនៅក្នុងដៃ ហើយបន្ទាប់មក ទោះបីជាករណីនេះមិនស្ថិតក្នុងការគ្របដណ្ដប់របស់ច្បាប់នេះក៏ដោយ ក៏ការអនុវត្តវិធានក្នុងលក្ខណៈជ្រើសរើសទៅលើករណីនៅក្នុងដៃបែបនេះ [...]។ ការបំពេញ*ចន្លោះប្រហោងក្រៅផ្លូវច្បាប់យ៉ាងធំធេង* ដោយការប្រៀប ធៀបបៀនេះ ក៏មានមូលដ្ឋានរបស់វាដោយការស្វែងរកនៅក្នុងការអនុវត្តជាក់ស្ដែង និងនៅក្នុងទ្រឹស្ដី – នៃភាពជាប់ទាក់ទងគ្នា និងភាពសម្បូរបែប [ការបង្ហាញ] នៃប្រព័ន្ធច្បាប់" (សេចក្ដីយោងយ៉ាងក្នុងត្រូវបានលុបចោល)។ *សូមមើល ផងែរ* A. Peczenik "'Analogia Legis. Analogy from Statutes in Continental Law" in Hubien, H. [Ed] *សំអាងហេតុ តាមផ្លូវច្បាប់។ កិច្ចដំណើរការនីតិវិធីនៃសន្និបាតពិភពលោកទស្សនៈវិជ្ជាខាងផ្លូវច្បាប់ និងសង្គម* ទីក្រុងប្រ៊ុចសែល ឆ្នាំ១៩៧១ ទំព័រ ៣៣២ ដែលយោងទៅក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៤៖ "*ការប្រៀបធៀប* គឺជាទឡ្ហីករណ៍*ខាងវោហារសាស្ត្រ* [...] ដែល ជាប់ទាក់ទងជាមួយគោលការណ៍នៃយុត្តិធម៌ដូចតទៅ៖ កម្មវត្ថុសំខាន់ៗដែលស្រដៀងគ្នា ត្រូវយកមកអនុវត្តក្នុងរបៀបប្រហាក់ ប្រហែលគ្នា។ ទឡ្ហីករណ៍ខាងវោហារសាស្ត្រ គឺមិនអាចជៀសរួចបានទេ នៅក្នុងការគិតពីផ្លូវច្បាប់ នៅក្នុងចំណោមមនុស្សជាច្រើន ដោយសារចៅក្រមមានកាតព្វកិច្ចត្រូវសម្រេចរឿងក្ដី បោះទោះបីជាច្បាប់ពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ (ឧទាហរណ៍ ក្រមណាប៉ូលេអុង កថាខណ្ឌ ៤ ការហាមឃាត់ចំពោះការបដិសេធមិនសម្រេចរឿងក្ដី "prohibition of *denegatio justitae*")។ Imre Zajte រៀបរាប់ដំណើរការនៃការសំអាងហេតុតាមផ្លូវច្បាប់ដោយលក្ខណៈប្រៀបធៀបមានដូចតទៅ៖ "ប្រភេទទីមួយនៃសំអាងហេតុតាមផ្លូវច្បាប់ដោយលក្ខណៈប្រៀបធៀបចាប់ផ្ដើមពីចំណុចដំបូងរបស់វានៅក្នុងវិធានដែលមានចែងដោយច្បាប់ ឬលក្ខន្តិកៈ។ ដំណើរការរួមមាន ទីមួយ ការស្រាវជ្រាវថាអ្វីទៅដែលបង្កើតបានជាសារៈសំខាន់បំផុតនៃវិធាននេះ ហើយចុងបញ្ចប់ តើអ្វីដែលបានដកហូតធាតុបន្ទាប់បន្សំរបស់វា: ហេតុដូច្នេះ វិធានដែលបានកាត់បន្ថយធាតុសំខាន់របស់វា ក្រោយមក នឹងត្រូវបានយមមកអនុវត្តចំពោះរឿងក្ដីមួយ ដែលខុសពីសម្មតិកម្មដែលច្បាប់បានចែងយ៉ាងច្បាស់លាស់ ទាក់ទងទៅនឹងធាតុបន្ទាប់បន្សំរបស់វា")។ Zajtay, I. "សំអាងហេតុដោយការប្រៀបធៀប គឺជាវិធីសាស្ត្រនៃការបកស្រាយ ច្បាប់" (ឆ្នាំ១៩៨០) *ព្រឹត្តប័ត្រសហកាល និងជាអន្តរជាតិនៃអាហ្វ្រិកខាងត្បូង* (13) 324, ទំព័រ ៣២៦។

[54] *សូមមើល សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ Paolo Stocchi* ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ៣៦ និងទំព័រ ១៧។

## III. បណ្តឹងឧទ្ធរណ៍ស្តីពីអង្គសេចក្តីនៃដីកាដំណោះស្រាយបច្ចុប្បន្ន ពុំពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន

២៧. ដោយសារដីកាដំណោះស្រាយត្រូវបានចាត់ទុកជាមោឃៈ (ពុំមានអត្ថិភាព និងគ្មានអានុភាពផ្លូវច្បាប់) ទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍លើអង្គសេចក្តី ក្លាយជាបញ្ហាដែលពុំមានការពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន។

២៨. មូលដ្ឋាន៦ នៃបណ្តឹងឧទ្ធរណ៍ ដែលបានផ្តល់ទឡ្ហីករណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ពាក់ព័ន្ធផ្ទាល់ជាមួយនឹងអង្គសេចក្តីនៃដីកាដំណោះស្រាយរបស់ ស.ច.ស.ជ[55]។ ស.ព.អ បានសន្និដ្ឋានថា ស.ច.ស.ជ "មានកំហុសអង្គច្បាប់ និងអង្គហេតុមួយចំនួន" នៅក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល ដែលរួមមាន៖

> (១) ការសម្រេចថា តាមការប៉ាន់ប្រមាណ និងជាបញ្ហាអង្គច្បាប់ ប្រភេទនៃ "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" អាចអនុវត្តបានចំពោះតែ ឌុច ម្នាក់គត់ប៉ុណ្ណោះ (២) ការបដិសេធពុំព្រមធ្វើការកំណត់បទចោទ និងទម្រង់នៃការទទួលខុសត្រូវ ដោយផ្អែកលើអង្គហេតុ ដែល ស.ច.ស បានទទួលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដូច្នេះហើយ ខកខានពុំបានចេញសេចក្តីសម្រេចដែលមានសំអាងហេតុ (៣) ការពិចារណា និងការវិភាគខុសចំពោះបញ្ហាថ្នាក់លើ និងការគាបសង្កត់ នៅក្នុងការវាយតម្លៃអំពីយុត្តាធិការបុគ្គល (៤) ការផ្តល់ទម្ងន់ហួសហេតុទៅលើ "ការចូលរួមដោយផ្ទាល់" នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម តែបែរជាមិនអើពើចំពោះទម្រង់នៃការទទួលខុសត្រូវដែលជាប់ពាក់ព័ន្ធច្រើនជាងនេះទៅវិញ (៥) ការសម្រេចដែលពុំមានមូលដ្ឋានអង្គហេតុ និង/ឬ ដែលផ្ទុយយ៉ាងច្បាស់ក្រឡែតទៅនឹងភ័ស្តុតាង និង (៦) ការផ្តល់ទម្ងន់ទៅលើកត្តានានា ដែលមានភាពជាប់ពាក់ព័ន្ធតិចតួចបំផុត នៅពេលធ្វើការវាយតម្លៃយុត្តាធិការបុគ្គល[56]។

២៩. ស.ព.អ ពុំបានលើកសេចក្តីសន្និដ្ឋានអំពីនីត្យានុកូលភាពនៃការចេញដីកាដំណោះស្រាយចំនួនពីរនោះទេ[57]។ ទោះបីជា ស.ព.អ បានធ្វើសេចក្តីសន្និដ្ឋានអំពី *ផលវិបាកនៃ*ដីកាដំណោះស្រាយពីរដោយឡែក និងផ្ទុយគ្នាក៏ដោយ ក៏គាត់ពុំបានលើកឡើងបញ្ហាចោទដើមគ្រាថាតើវាស្របតាមច្បាប់

---

[55] បណ្តឹងឧទ្ធរណ៍ របស់ ស.ព.អ កថាខណ្ឌ ២០ ដល់ ១៦៣។

[56] *ដូចខាងលើ* កថាខណ្ឌ ១៩។

[57] *ដូចខាងលើ* កថាខណ្ឌ ១៩។

ដែរឬទេតាំងពីដំបូងមក[58]។ បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ បានធ្វើឡើងដោយផ្អែកលើការសន្មត មានកំហុសថា ស.ច.ស ត្រូវបានអនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដាច់ចេញពីគ្នា។ ស.ព.អ បានសន្មតថា បញ្ហានីតិវិធីស្នូលចំពោះ អ.ប.ជ គឺថាតើគួរបន្តកិច្ចដំណើរការនីតិវិធីនៅពេលដែលមានការយល់ឃើញផ្ទុយគ្នារវាងចៅក្រមជាតិ និងអន្តរជាតិដែរឬទេ និងនៅពេលមិនមានសម្លេងភាគច្រើនលើសលប់ អនុលោមតាមមាត្រា ៧(៤) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[59]។ ស.ព.អ បានដាក់ជូនការយល់ឃើញចំពោះ "អ្វីដែលត្រូវធ្វើ ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចដោះស្រាយភាពមិនស្របគ្នារវាង ស.ច.ស បាន" [60] ដោយពុំបានឆ្លើយតបទៅនឹងសេណារីយ៉ូ អ.ប.ជ ជាឯកច្ឆ័ន្ទ។

៣០. ពុំមានទម្លាប់ករណ៍ផ្លូវច្បាប់បន្ថែមដើម្បីឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ[61] ហើយបណ្ដឹងឧទ្ធរណ៍ត្រូវបានចាត់ទុកឥតបានការ នៅក្នុងន័យថា "ពុំមានសារសំខាន់ជាក់ស្ដែង"[62]។ ចៅក្រម អ.វ.ត.ក បានទទួលស្គាល់ស្ថានការណ៍ដែលសេចក្ដីសម្រេច ឬ ឯកសារ ត្រូវបានចាត់ទុក "ឥតបានការ" ដោយសារគ្មានបញ្ហាចោទជាក់ស្ដែងសម្រាប់តុលាការសម្រេច[63]។ ឧទាហរណ៍

---

[58] *ដូចខាងលើ* កថាខណ្ឌ ១៦៤ ដល់ ១៦៥។

[59] *ដូចខាងលើ* កថាខណ្ឌ ១៧៤។

[60] *ដូចខាងលើ* កថាខណ្ឌ ១៧៤។

[61] សម្រាប់មូលហេតុដូចគ្នានេះ ទម្លាប់ករណ៍របស់តុលាការជាន់ខ្ពស់ទៅលើអង្គសេចក្ដី ដែលបានដាក់ជូនដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានធ្វើឡើងដោយមិនជាប់ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះទេ។ ការមិនឆ្លើយតបរបស់មេធាវីការពារក្ដីទៅនឹង *បណ្ដឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងទឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង ០០៤* មិនគួរចាត់ទុកថាជាការទទួលយកដោយតុណ្ហីភាពនៃទម្លាប់ករណ៍ដែលមាននៅក្នុងបណ្ដឹងឧទ្ធរណ៍នោះឡើយ។

[62] Garner, B., [Ed.] វចនានុក្រម *Black's Law* បោះពុម្ពលើកទី៩ ទំព័រ ១០៩៩។

[63] *សូមមើល សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣០ ដល់ ៣២។ *សូមមើល ផងដែរ សេចក្ដីជូនដំណឹងពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅភាគីនានាស្ដីពីការចេញសាឡើងវិញនូវដីកាសម្រេចដែលចៅក្រម Harmon បានសម្រេចនៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥ ឬបន្ទាប់ពីកាលបរិច្ឆេទនេះ* ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D262 កថាខណ្ឌ ២ ដល់ ៤។ ស.ច.ស.អ Bohlander បានសម្រេចថា សេចក្ដីសម្រេច ចេញដោយ ស.ច.ស.អ Harmon ក្រោយគាត់ចូលកាន់តំណែងបានបញ្ចប់ទៅ គឺមិនមានអានុភាពទេ ដោយសារតែចៅក្រម Harmon *លែងមានសិទ្ធិអំណាចទៀតហើយ* នៅពេលគាត់ចេញដីកាសម្រេចទាំងនោះ។ ស.ច.ស.អ Bohlander បានជូនដំណឹងដល់ភាគីថា "ដីកាសម្រេចណាដែលអាចប្ដឹងឧទ្ធរណ៍ នឹងក្លាយជាដីកាសម្រេចលែងមានសុពលភាព" នៅពេល

អ.ប.ជ បានរកឃើញនៅក្នុង*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ*

---

ដែលគាត់ចេញសាជាថ្មីឡើងវិញនូវដីកាសម្រេចថ្មី។ សំណុំរឿង ០០៣ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត* Harmon *អំពីបទចោទប្រកាន់ប្រឆាំង មាស មុត* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D128.1/1/11 កថាខណ្ឌ ៦ ដល់ ៨។ ស.ច.ស.អ Bohlander បានលុបចោលបទចោទដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ ស.ច.ស.អ Bohlander ដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ*ដោយកំបាំងមុខ* និងបានជូនដំណឹងដល់ មាស មុត ថា "ការចោទប្រកាន់ដែលមាននៅក្នុងសេចក្តីសម្រេចនេះ លែងមានសុពលភាព"។ នៅពេល មាស មុត ដាក់បណ្តឹងឧទ្ធរណ៍សាជាថ្មីប្រឆាំងនឹងការចោទប្រកាន់របស់ ស.ច.ស.អ Bohlander អ.ប.ជ បានសម្រេចថា បណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងបទចោទរបស់ ស.ច.ស.អ Harmon "លែងមានសុពលភាពហើយ ហើយគួរត្រូវបានបដិសេធចោល"។ *ដីកាសម្រេចបន្ថែមលើសំណើបន្ទាន់សុំធ្វើការពិចម្ងាយ* ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D321/4 កថាខណ្ឌ ២ និង ៥ ដល់ ៧។ ស.ច.ស.អ បានប្រកាសមោឃភាពទៅលើ*សំណើបន្ទាន់របស់ អោ អាន សុំធ្វើការពិចម្ងាយ* ដោយសារតែសំណើរបស់អង្គភាពគាំពារការការពារក្តីចំពោះកិច្ចសន្យាការងារថ្មីសម្រាប់ទីប្រឹក្សាច្បាប់។ សំណុំរឿង ០០៤/០១ *ដីកាសម្រេចលើសំណើសុំបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ទៅអង្គបុរេជំនុំជម្រះ* ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤ ឯកសារ D207/1 កថាខណ្ឌ ៣៥ និង ៣៨។ ស.ច.ស.អ បានប្រកាសមោឃភាពលើសំណើរបស់អ្នកស្រី អ៊ឹម ចែម សុំឱ្យបង្អង់ដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ ដោយសារតែគាត់ខកខានមិនបានចូលមកបង្ហាញខ្លួនជាបឋមរបស់គាត់តាមពេលកំណត់ និងការកត់សម្គាល់របស់សហមេធាវីការពារក្តីគាត់ថា លោកស្រីនឹងមិនចូលខ្លួនកាន់ អ.វ.ត.ក មកដោយស្ម័គ្រចិត្តនោះទេ ព្រមទាំងការបដិសេធរបស់ អ.ប.ជ ទៅលើសំណើរបស់គាត់សុំផ្អាកការកោះហៅ។ សំណុំរឿង ០០៤/០២ *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ* ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ១១, ២០, ៣៨ និង ៣៩។ ស.ច.ស.អ បានប្រកាសមោឃភាពលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ ថាតើសហព្រះរាជអាជ្ញាអាចនឹងដាក់ដីកាសន្និដ្ឋានស្ថាពរដាក់ដោយឡែកឬយ៉ាងណា ហើយផលប៉ះពាល់ពីការមិនចុះសម្រុងគ្នារវាងសហព្រះរាជអាជ្ញា អាចមានទៅលើពេលវេលានៃការដាក់ដីកាសន្និដ្ឋានស្ថាពរ ដោយហេតុថា សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ពួកគាត់រួចទៅហើយ។ បន្ថែមលើនេះទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិបានប្រកាស "មោឃភាព" ចំពោះការដាក់សំណើ និងសេចក្តីសម្រេចនានា ដោយសារលែងមានវិវាទសម្រាប់ឱ្យតុលាការនេះដោះស្រាយតទៅទៀតហើយ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការ MICT រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Karadžić* (MICT-13-55-A) "សាលដីកាសម្រេចលើសំណើសុំឱ្យដកហូតចៅក្រម Theodor Meron" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ទំព័រ ២។ ចៅក្រម Meron បានសម្រេចដកខ្លួនចេញពីសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Karadžić* ក្តី, rendering the Defence motion to disqualify him moot. អង្គជំនុំជម្រះសាលាដំបូងតុលាការ MICT រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Nikolić* (MICT-14-65-ES) "អត្ថបទសាធារណៈ មានកោសលុប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ ស្តីពីសំណើរបស់ Ratko Mladić សុំការអនុញ្ញាតដើម្បីធ្វើការឆ្លើយតប និងការពិចារណាឡើងវិញ ឬនិយាយម្យ៉ាងទៀតថា ការបញ្ជាក់បំភ្លឺ ឬការដកហូត" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ២៨ លេខជើងទំព័រយោង ៥២ ("យោងទៅលើការណ៍ដែលថា យើងនឹងទទួលយកសំណើរបស់ Mladić សុំឱ្យមានការពិចារណាឡើងវិញដោយផ្នែក តាមរយៈនេះ យើងសូមប្រកាសមោឃភាពទៅលើសំណើជាជម្រើសនានារបស់ Mladić សុំការបញ្ជាក់បំភ្លឺសម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសិទ្ធិទទួលបាន ឬសម្រាប់ការប្តឹងសុំឱ្យដកហូតរូបខ្ញុំ")។

*ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទនៅគុកលេខ ៨ និងនៅក្នុងស្រុកបាកាន* ថា សំណើសុំរបស់ ស.ព.អ សុំបំពេញកិច្ចស៊ើបសួរត្រូវបានចាត់ទុកជាឥតបានការ ដោយសារពុំបានដីកាបញ្ជូន ហើយវាគ្រាន់ជាការប៉ាន់ស្មានក្នុងការពិចារណាថាតើ ស.ច.ស "ធ្វើការបកស្រាយផ្សេងទៅលើវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង"[64]។

៣១. អាស្រ័យហេតុនេះ ដំណោះស្រាយទៅលើបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ មិនមានផលវិបាក ហើយជាកម្មវត្ថុនៃការច្រានចោលជាបន្ទាន់[65]។

## សេចក្ដីសន្និដ្ឋាន

៣២. ក្រោយដំណើរការនីតិវិធីនៅក្នុងដំណាក់កាលអង្គបុរេជំនុំជម្រះរយៈពេលជាង ១៣ ឆ្នាំ រឿងក្ដីរបស់លោក យឹម ទិត្យ បានចូលដល់ស្ថានភាពរបស់ Kafkaesque ដែលក្នុងនោះ បណ្ដឹងឧទ្ធរណ៍របស់ភាគីនឹងត្រូវបើកសវនាការដោយអង្គជំនុំជម្រះដែលសម្រេចជាឯកច្ឆ័ន្ទលើដីកាដែលត្រូវបានជំទាស់ ថាជាដីកាពុំមានមូលដ្ឋាននីតិវិធីនៅក្នុងច្បាប់។ ដូច អ.ប.ជ បានកត់សម្គាល់ វាហាក់ដូចពុំដែលកើតមាន "នៅក្នុងប្រវត្តិសាស្ត្រជាតិ ឬប្រព័ន្ធច្បាប់អន្តរជាតិ ដែលសំណុំរឿងព្រហ្មទណ្ឌមួយមានលក្ខណៈប្រហាក់ប្រហែលនឹងការចេញសេចក្ដីសម្រេចពីរដែលផ្ទុយគ្នា ក្នុងពេលតែមួយដោយអង្គភាពតុលាការតែមួយនោះ"[66]។ យើងពុំដែលឃើញមានការជំនុំជម្រះរឿងក្ដីព្រហ្មទណ្ឌដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះខុសច្បាប់ និងមិនមានសុពលភាពបែបនេះទេ។

៣៣. អ.ប.ជ បានប្រកាសរួចហើយអំពីភាពខុសច្បាប់នៃការចេញដីកាដំណោះស្រាយចំនួនពីរ ដូច្នេះលទ្ធផលនៃ*បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ* ពុំអាចគេចផុត និងមានរួចហើយ។ ដំណោះស្រាយ *ផ្លូវច្បាប់* តែមួយគត់ចំពោះចៅក្រម អ.ប.ជ នៅដំណាក់កាលនេះ គឺត្រូវរកដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយនានាដែលបានស្នើ

---

[64] *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ៨ និងនៅក្នុងស្រុកបាកាន* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣០ ដល់ ៣២។

[65] ក្នុងសំណុំរឿង ០០៤/២ អ.ប.ជ បានប្រកាសថា ខ្លួនមិនអាចឈានដល់ការទទួលបានសំឡេងភាគច្រើនលើសលប់ ស្របតាមមាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលទាក់ទងតែនឹង "ការមិនទទួលបានសំឡេងគាំទ្រចំនួនតាមការកំណត់ ដើម្បីឈានទៅសេចក្ដីសម្រេចផ្អែកលើសំអាងហេតុរួម*លើអង្គសេចក្ដី*ឡើយ"។ សេចក្ដីពិចារណាលើសុះំនុំរឿអ ០០៤/២ កថាខណ្ឌ ១៦៩។

[66] សេចក្ដីពិចារណាលើសំណុំរឿង ០០៤/២ កថាខណ្ឌ ១២៤។

ឡើងនៅក្នុង *បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ* គឺច្រានចោលដីកាដំណោះស្រាយដែលមានវិការៈទាំងស្រុងជាអចិន្ត្រៃយ៍[67] ច្រានចោលដីកាដំណោះស្រាយដែលមានវិការៈ និងបង្វិលសំណុំ រឿងទៅ ស.ច.ស វិញ[68] ឬ ច្រានចោលដីកាដំណោះស្រាយដែលមានវិការៈ វាយតម្លៃសំណុំរឿង និងចេញដីកាដំណោះស្រាយដោយខ្លួនឯង[69]។ ក្នុងករណីបំពេញកិច្ចខុសពីនេះ កិច្ចដំណើការនីតិវិធីដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះចេញដោយខុសច្បាប់ នឹងរំលោភសិទ្ធិជាមូលដ្ឋានរបស់ លោក យឹម ទិត្យ ចំពោះការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយជៀសមិនរួច។ អ.ប.ជ ត្រូវសម្រេចលើកិច្ចរបស់ ស.ច.ស ដែលបានធ្វើឡើងហួសដែនអំណាចដោយផ្តល់ដំណោះស្រាយ ណាមួយក្នុងចំណោមដំណោះស្រាយទាំងនេះ។

៣៤. មេធាវីការពារក្តីសូមរម្លឹកថា ការទទួលខុសត្រូវសំខាន់របស់ អ.ប.ជ គឺការធានានូវយុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់ការមុនការជំនុំជម្រះ ដោយការងារសំខាន់បំផុត គឺថា អ.ប.ជ ត្រូវបំពេញកាតព្វកិច្ចក្នុងការធានានូវកិច្ចដំណើរការនីតិវិធី អ.វ.ត.ក ស្របច្បាប់ ជាជាងធ្វើឡើង

---

[67] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨។ ច្បាប់បង្កើត អ.វ.ត.ក មាត្រា ៣៥ *ថ្មី*។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ ICCPR មាត្រា ១៤(២)។

[68] វិធា ៧៦(៥) នៃវិធានផ្ទៃក្នុង។ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣១ និងមាត្រា ៣៨។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៥១។ ច្បាប់បង្កើត អ.វ.ត.ក មាត្រា ៣៥ *ថ្មី*។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ ICCPR មាត្រា ១៤(២)។ *សូមមើល ផងដែរ* សំណុំរឿង ០០៤/០១ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២២។

[69] វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៥១។ ច្បាប់បង្កើត អ.វ.ត.ក មាត្រា ៣៥ *ថ្មី*។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ ICCPR មាត្រា ១៤(២)។ *សូមមើល ផងដែរ* សំណុំរឿង ០០៤/១ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២២។ សំណុំរឿង ០០១ *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេចអ៊ាវ ហៅ "ឌុច"* ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៤០។ *សូមមើល ផងដែរ* សំណុំរឿង ០០៤/១ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២២។ អ.ប.ជ "បំពេញតួនាទីជាសភាស៊ើបសួរស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានៃព្រះរាជាណាចក្រកម្ពុជានៅក្នុង អ.វ.ត.ក" ហើយនៅពេលទទួលបានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ "វិធាន ៧៩(១) នៃវិធានផ្ទៃក្នុងស្នើឡើងថា [អ.ប.ជ] មានអំណាចចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះស្រាយដែលបានកែប្រែរួច ដែលនឹងយកមកធ្វើជាមូលដ្ឋាននៃការជំនុំជម្រះ"។

តាមចិត្ត[70]។ ដោយសារវិធាន ៧៦ (៧) កំណត់ថា សុពលភាពនៃនីតិវិធីនៅក្នុងកិច្ចស៊ើបសួរមិន អាចលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល អ.ប.ជ គឺជាយន្តការចុងក្រោយក្នុងការកែតម្រូវកិច្ចនីតិវិធីខុសច្បាប់របស់ ស.ច.ស។ អ.ប.ជ ត្រូវបំពេញកិច្ចជាក់លាក់ស្របតាមការសម្រេចជាឯកច្ឆ័ន្ទរបស់ខ្លួន។

## ដំណោះស្រាយ

អាស្រ័យហេតុនេះ ផ្អែកលើហេតុផលដូចបានលើកឡើងនៅក្នុងចម្លើយតបនេះ ដើម្បីអនុវត្តឆន្ទានុសិទ្ធិ និងជាផលប្រយោជន៍នៃយុត្តិធម៌ មេធាវីការពារក្តីសូមគោរពស្នើសុំឲ្យអង្គបុរេជំនុំជម្រះ៖

(១) **ច្រានចោល**បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ និង

(២) **ច្រានចោល**ដីកាដំណោះស្រាយដែលមានវិការៈទាំងស្រុងជាអចិន្ត្រៃយ៍ និងលើកលែងការចោទប្រកាន់លោក យឹម ទិត្យ *ឬ*

(៣) **ច្រានចោល**ដីកាដំណោះស្រាយដែលមានវិការៈ និងបង្វិលសំណុំរឿងទៅ ស.ច.ស ដោយបង្គាប់ឲ្យចេញដីកាដំណោះស្រាយរួមគ្នាស្របតាមច្បាប់ជាធរមាន ព្រមទាំងបញ្ជាក់ថាការបន្តខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយផ្តល់ប្រយោជន៍ដល់លោក យឹម ទិត្យ *ឬ*

(៤) **ច្រានចោល**ដីកាដំណោះស្រាយដែលមានវិការៈ វាយតម្លៃសំណុំរឿង ០០៤ និងចេញដីកាដំណោះស្រាយ ដោយចោទប្រកាន់បញ្ជូនលោក យឹម ទិត្យ ទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ចំពោះលោក។

សូមលោកចៅក្រមទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

សូ មូស្សេនី | Suzana TOMANOVIĆ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០

[70] សំណុំរឿង ០០៤/២ *សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន* ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D360/3 កថាខណ្ឌ ៦។ អ.ប.ជ យល់ឃើញថា "វាមានលក្ខណៈសមស្របក្នុងការអនុវត្តយុត្តាធិការដែលខ្លួនទទួលបាន ក្នុងនាមជាអង្គជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍ នៅដំណាក់កាលមុនអង្គសេចក្តី និងនៅពេលពុំមានសេចក្តីសម្រេចជាក់លាក់ណាមួយ [...] ដើម្បីផលប្រយោជន៍នៃយុត្តិធម៌"។